# យើងជឿថាបញ្ហាសុខភាពរបស់កុមារអាចដោះស្រាយបាន។

## ការណែនាំអំពីទឹកដោះម្ដាយរបស់ GenV

- **ទារកអាយុតិចជាងមួយសប្ដាហ៍?** ប្រមូលសំណាកនៅអាយុ 7 ថ្ងៃ ឬឱ្យបានឆាប់តាមដែលអ្នកអាចធ្វើទៅបាន បន្ទាប់ពីពេលនោះ។
- **ទារកមានអាយុលើសពីមួយសប្ដាហ៍?** ប្រមូលសំណាកឱ្យបានឆាប់តាមដែលអ្នកអាចធ្វើទៅបាន
- **ភ្លេច ឬពិបាកប្រមូល?** បញ្ជូនសំណាករបស់អ្នកនៅពេលណាក៏បានដែរ -សំណាកនីមួយៗមានសារៈសំខាន់
- វាអាចងាយស្រួលជាងក្នុងការប្រមូលទឹកដោះមុនពេលបំបៅ - បន្ទាប់ពីបំបៅរួចក៏មិនអីដែរ។

តើបានធ្វើបាត់កញ្ចប់ ឬធ្វើខុសមែនទេ? - ទាក់ទងមកពួកយើង៖

ទូរសព្ទ៖ 1800 436 888 គេហទំព័រ៖ www.genv.org.au

**ព័ត៌មានស្ដីពីសុវត្ថិភាព៖**
ទុកឱ្យឆ្ងាយពីកុមារ។ កុំឱ្យកុមារប៉ះបំពង់។
បំពង់មានផ្ទុកម្សៅខ្លះ។ វាមានសុវត្ថិភាព ប៉ុន្តែវាអាចធ្វើឱ្យក្រហាយភ្នែក ស្បែក ឬផ្លូវដង្ហើម។
ប្រសិនបើម្សៅប៉ះស្បែក ឬភ្នែក - ចូរលាងជម្រះជាមួយទឹក។
ស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ ប្រសិនបើការក្រហាយនៅតែបន្តកើតមាន។

**1**

អ្នកត្រូវការ៖
- ប័ណ្ណណែនាំនេះ
- បំពង់ប្រមូលទឹកដោះរបស់អ្នក
- ថង់ដែលមានបន្ទះស្រូបជាតិទឹកមួយសន្លឹក
- ក្រដាសជូតសម្អាតទារកពីរសន្លឹក (មិនមានផ្ដល់ជូនទេ)
- ប៊ិចមួយ (មិនមានផ្ដល់ជូនទេ)

**2**



- ជ្រើសរើសដោះមួយណាដែលត្រូវច្របាច់យកទឹកដោះ
- ដោះមួយណាក៏បានដែរ មិនអីទេ
- សម្អាតដោះ ក្បាលដោះ និងតំបន់នៅក្បែរក្បាលដោះ ជាមួយក្រដាសជូតសម្អាតទារក

**3**



- យកគម្របចេញពីបំពង់ប្រមូលទឹកដោះ
- ព្យាយាមកុំឱ្យកំពប់ម្សៅនៅខាងក្នុង

**4**



- ច្របាច់ទឹកដោះចូលទៅក្នុងបំពង់
- អ្នកអាចប្រើប្រដាប់បូមយកទឹកដោះដែលស្អាតជំនួសវិញ - បន្ទាប់មកចាក់ទឹកដោះចូលទៅក្នុងបំពង់
- ព្យាយាមបំពេញឱ្យបានពាក់កណ្ដាលបំពង់ (ប្រមាណជាមួយស្លាបព្រាកាហ្វេ)
- ប្រសិនបើអ្នកមិនអាចប្រមូលបានបរិមាណនេះទេ ចូរប្រមូលឱ្យបានច្រើនតាមដែលអ្នកអាចធ្វើទៅបាន

**5**




- **បិទគម្របនៅលើបំពង់វិញ** - ពិនិត្យមើលថាវាបានបិទយ៉ាងតឹង
- សម្អាតដោះ ក្បាលដោះ និងតំបន់នៅក្បែរក្បាលដោះម្ដងទៀត ជាមួយក្រដាសជូតសម្អាតទារក
- ចុះកាលបរិច្ឆេទ និងពេលវេលានៅលើបំពង់ទឹកដោះ នៅត្រង់កន្លែងដែលសរសេរថា 'កាលបរិច្ឆេទ និងពេលវេលាប្រមូល' (**'Date and Time Collected'**)

**6**




- ដាក់បំពង់ចូលទៅក្នុងថង់ដែលមានបន្ទះស្រូបជាតិទឹក
- សង្កត់គែមថង់ភ្ជាប់គ្នាដើម្បីបិទភ្ជាប់ - ឱ្យមានខ្យល់តិចបំផុតតាមដែលអ្នកអាចធ្វើទៅបាន

**7**




- ដាក់ថង់ទៅក្នុងស្រោមសំបុត្រឆ្លើយតបបង់ថ្លៃតែមរួចស្រេច
- បិទស្រោមសំបុត្រ
- អាចដាក់វានៅកន្លែងមានសីតុណ្ហភាពបន្ទប់ (មិននៅក្នុងទូទឹកកក ឬទូបង្កក)

**8**




- ផ្ញើសំណាកទៅ GenV ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការប្រមូល
- ប្រើប្រអប់ប្រៃសណីយ៍អូស្ត្រាលីណាមួយក៏បាន
- មិនចាំបាច់ត្រូវការតែមទេ

**9**

- ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមស្កេនកូដ QR
- វាភ្ជាប់ទៅនឹង 'ការណែនាំដើម្បីប្រមូលសំណាកជីវសាស្ត្រ នៅលើគេហទំព័រ GenV'

V1.0 2022-06-28

**សូមអរគុណដែលបានជួយធ្វើឱ្យមនុស្សជំនាន់ក្រោយ ជាជំនាន់ដែលមានសុខភាពល្អបំផុត។**